ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក**
FORTUNE BROAD FOOTWEAR CO.,LTD.
អាសយដ្ឋាន៖ ភូមិអង្គស្នួលទី២ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្ដាល

**កិច្ចព្រមព្រៀង**
**រវាង**
**នាយកក្រុមហ៊ុន ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក**
**ជាមួយប្រតិភូបុគ្គលិក ប្រចាំក្រុមហ៊ុនហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក**
**ស្តីពីការព្យួរកិច្ចសន្យាការងារ**

FORTUNE BROAD FOOTWEAR CO.,LTD. 公司协理与员工代表之间的协议书
关于暂停工作合同

ឆ្នាំពីរពាន់ម្ភៃបី ខែមីនា ថ្ងៃទី ២០ វេលាម៉ោងប្រាំបួនគត់ នៅការិយាល័យក្រុមហ៊ុន **ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក / FORTUNE BROAD FOOTWEAR CO.,LTD**

មានកិច្ចប្រជុំពិភាក្សា រវាង**នាយកក្រុមហ៊ុន** និង **ប្រតិភូ-បុគ្គលិកប្រចាំក្រុមហ៊ុន ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក** ស្តីពីការ**ព្យួរកិច្ចសន្យាការងារជាលើកទី៣។** ដោយមូលហេតុ ក្រុមហ៊ុនរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺ**កូវិដ-១៩** បណ្ដាលឱ្យក្រុមហ៊ុន**គ្មានការបញ្ជាទិញនៅឡើយ។**

2023 年 03 月 20 号 09 点钟，在富弘鞋业有限公司举行了一个会议，由公司协理和富弘员工代表参加，谈论关于第三次暂停员工工作合同。由于疫情严重爆发，使公司还是没有订单。

ហេតុនេះ ក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖

由此，经谈论后，双方认定如下：

ភាគីទាំងពីរយល់ព្រមព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១០៣នាក់រយៈពេលពីរខែ គឺចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣១ ខែ ឧសភាឆ្នាំ២០២៣។

双方同意暂停工作合同 103 人为 2 个月。即 **2023** 年 **04** 月 **01** 号至 **2023** 年 **05** 月 **31** 号为止。

1- ភាគីទាំងពីរយល់ព្រមទទួលយក ការផ្ដល់ប្រាក់ឧបត្ថមចំនួន ៣០$ ដុល្លារអាមេរិក សម្រាប់កម្មករ និយោជិតម្នាក់ៗ ក្នុងមួយខែ នៃរយៈពេលព្យួរកិច្ចសន្យាការងារខាងលើ ក្នុងនោះ៖
   - ចំនួន ១៥ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
   - ចំនួន ៣០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ

   双方同意关于以上暂停员工工作合同期间，给予每员工一个月 **30** 美元其中：
   - 停工 07 天到 14 天，提供 15 美元
   - 停工 15 天到 **1** 个月，提供 **30** 美元

2- ក្រុមហ៊ុននឹងរៀបចំបញ្ជីរាយនាមកម្មករ និយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារតាមទម្រង់ឧបសម្ព័ន្ធទី៣ នៃសេចក្ដីណែនាំលេខ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០២៣ របស់ក្រសួងការងារ

និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដោយតម្រូវឱ្យកម្មករ និយោជិតផ្តិតមេដៃលើឈ្មោះរបស់ខ្លួន ដើម្បីបញ្ជាក់ថា លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង លេខទូរស័ព្ទដែលបងប្អូន កម្មករ និយោជិតបានផ្តល់ មកឱ្យរដ្ឋបាលក្រុមហ៊ុន គឺត្រឹមត្រូវ ដើម្បីក្រសួងយកទៅធ្វើជាមូលដ្ឋានសម្រាប់ផ្ទេរប្រាក់ឧបត្ថមចំនួន ៤០$ ដុល្លារអាមេរិក ក្នុង១ខែ (អំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ) ជូនបងប្អូនកម្មករ និយោជិតតាមរយៈធនាគារឯកទេសវីង ក្នុងនោះ។

- ចំនួន ២០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ចំនួន ៤០ ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ

公司将按 020/23 ក.ប/ស.ណ.ន.ខ.ល 劳工部于 2023 年 03 月 15 日颁布指示的附件 3，并要求被停工的员工在其姓名按上手印，以确保员工所给人事部提供的身份证号码和电话号码是正确。为了使劳工部以此为基础通过 WING 银行给员工汇款一个月 **40** 美元（暂停工作期间）。

- 停工 **7** 天到 **14** 天，提供 **20** 美元
- 停工 **15** 天到 **1** 个月，提供 **40** 美元

3- ក្នុងករណីបងប្អូនកម្មករ និយោជិតមិនបានចូលធ្វើការវិញតាមកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ ស្តីពីការងារ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

如果员工没有按指定日返回工作，公司将按劳工法和公司规章执行。

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២៣

2023 年 03 月 20日

ស្នាមមេដៃប្រតិភូបុគ្គលិក និង ប្រធានក្រុម ប្រចាំក្រុមហ៊ុន ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក

**នាយកក្រុមហ៊ុន** / 公司协理

ព្រះរាជាណាចក្រកម្ពុជា
ហ្វ័រឈូន ប្រត ហ្វ៊ូតវែរ ឯ.ក
FORTUNE BROAD FOOTWEAR CO.,LTD.
KINGDOM OF CAMBODIA

**CHEN CHIN PI**

ទេព សឿន

ផន ធីតា

បូ សុផាត

អាន សុផៃ

ម៉ាល់ តីសាស់

ប៉ែន ចន្ទូ

ជាង ស៊ីនួន

ទួន សុខណម

ប៉ូរ សុទៀង

ធុន សុខហេង

សំ មុំ

រីម សុវណ្ណ